



(Salat Eid)

របៀបសឡាតរ៉យ៉ាទាំងពីរ (كيفية صلاة العيدين)

#ចំនួនរ៉ក្អាត់ ៖ អំពីចំនួនរ៉ក្អាត់នៃសឡាតថ្ងៃរ៉យ៉ា គឺមានតែ២រ៉ក្អាត់ប៉ុណ្ណោះ ដោយយោងទៅលើហាទីសរ៉ស៊ូលុលឡោះ រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម អំពី អ៊ីបនូ អាប់ហ្គាស (ابن عباس) ថា ៖ រ៉ស៊ូលុលឡោះបានចេញពីផ្ទះដើម្បីទៅសឡាតថ្ងៃរ៉យ៉ា (يومَ الفطرِ) គាត់បានសឡាតតែ២រ៉ក្អាត់ប៉ុណ្ណោះ គាត់ក៏មិនបានសឡាតស៊ុណ្ណោះមុន ឬក្រោយនៃសឡាតថ្ងៃរ៉យ៉ាឡើយ ។

#ចំនួនតឹកពៀត ៖ មាន១២តឹកពៀត រ៉ក្អាត់ទី១មាន «៧តឹកពៀត» រីឯ រ៉ក្អាត់ទី២មាន «៥តឹកពៀត» ។

- រ៉ក្អាត់ទី១ ៖ ត្រូវសូត្រ ៧តឹកពៀត(الله أكبر) ដោយក្នុង៧តឹកពៀតនោះ គឺមានតឹកពៀតរ៉តុលអៀហរ៉មមួយផងដែរ មានន័យថា ពេលដែលចាប់ផ្តើមសឡាត គឺត្រូវសូត្រ الله أكبر ដំបូងគេបង្អស់ នេះហៅថា តឹកពៀតរ៉តុលអៀហរ៉ម (تكبيرة الإحرام) បន្ទាប់មកសូត្រ ៦តឹកពៀតទៀត សរុបទាំងអស់ គឺមាន៧តឹកពៀត ក្នុងរ៉ក្អាត់ទី១ ។

ហើយក្នុងរ៉ក្អាត់ទី១ដដែល បន្ទាប់ពីសូត្រ الله أكبر មុនគេបង្អស់ ដែលហៅថាតឹកពៀតរ៉តុលអៀហរ៉មនោះរួច ត្រូវសូត្រទូអា អាល់អ៊ីសតីហ្វតាហ (الإستفتاح) ថា ៖

سُبْحَانَكَ اللَّهُمَّ وَبِحَمْدِكَ. تَبَارَكَ اسْمُكَ وَتَعَالَى جَدُّكَ. وَلاَ إِلهَ غَيْرُكَ". رواه مسلم"

បន្ទាប់ពីសូត្រទូអា الاستفتاح នោះរួច ត្រូវសូត្រ الله أكبر (ចំនួន៦ដង) បន្ទាប់មកសូត្រ ៖ أعوذُ باللهِ من الشيطانِ الرَّجيمِ

បន្ទាប់មកសូត្រ ៖

بسم الله الرحمن الرحيم

រួចសូត្រ ៖ ស៊ូរ៉ោះ អាល់ហ្វាទីហះ ។

- រ៉ក្អាត់ទី២ ៖ ត្រូវសូត្រ ៥តឹកពៀត(الله أكبر) ចំណែកឯតឹកពៀតពេលក្រោកពីស៊ូជូទនោះមិនស្ថិតនៅក្នុងចំណោម៥តឹកពៀតនេះទេ ។

ក្នុងរ៉ក្អាត់ទី២នេះដែរ បន្ទាប់ពីសូត្រ الله أكبر បាន៥ដងហើយនោះ មិនបាច់សូត្រ ៖ أعوذُ بالله من الشيطانِ الرَّجيمِ ទៀតនោះទេ គឺចាប់ផ្ដើមពី بسم الله الرحمن الرحيم និងសូត្រស៊ូរ៉ោះ អាល់ហ្វាទីហះតែម្ដង ។

>> ភស្តុតាងអំពីចំនួន ១២តឹកពៀត (រ៉ក្អាត់ទីមួយ៧ រីឯរ៉ក្អាត់ទីពីរ៥) យោងទៅលើហាទីស ៖

عن عمرو بن شعيب عن أبيه عن جده (أنَّ النبيَّ صلى الله عليه وسلم كبَّر في عيدٍ اثْنَتَي عشْرَةَ تكبيرةً سبْعًا في الأُولَى وخمْسًا في الآخِرَةِ ولمْ يُصلِّ قبلَهَا ولا بعدَهَا) مسند أحمد اسناده صحيح

Caption

ទោះបីជាបែបនេះក្ដី ដូច អ៊ីម៉ាំ អះម៉ាត់ ថា ៖ សោះហ្កាត់រ៉ស៊ូលុលឡោះមួយចំនួនបានយល់ឃើញផ្ទុយពីនោះ អំពីចំនួនតឹកពៀតខាងលើ ។

ដូចស្ហៃខ អ៊ីបនូ អ៊ូសៃមីន ថា ៖ ការដែលអ្នកសូត្រ ១២តឹកពៀត (រ៉ក្អាត់ទីមួយ៧-ទីពីរ៥) ជារឿងដែលល្អ ហើយបើសិនជាអ្នកធ្វើផ្សេងពីនោះក៏ត្រឹមត្រូវដូចគ្នាដែរ ហើយពេលតឹកពៀត الله أكبر ត្រូវលើកដៃទាំងពីរផងដែរ ពីព្រោះវាជាស៊ុណ្ណះរ៉ស៊ូលុលឡោះ ។

#ការសូត្រក្នុងចន្លោះតឹកពៀតនីមួយៗ ៖

ក្នុងចន្លោះតឹកពៀតនីមួយៗពេលសឡាតថ្ងៃរ៉យ៉ា ស៊ុណ្ណះត្រូវសូត្រថា ៖

الله أكبرُ كَبِيرًا ، وَالْحَمْدُ لِلَّهِ كثيرًا ، وَسُبْحَانَ الله بُكرةً وَأَصِيلًا ـ اَللَّهُمَّ صَلِّ عَلَى مُحَمَّد

ឬសូត្រម្យ៉ាងទៀតបានដូចគ្នា ៖

الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ - اَللَّهُمَّ صَلِّ عَلَى مُحَمَّد

ទូអាខាងលើនេះ យោងទៅលើហាទីស អ៊ីបនូ ម៉ាស់អ៊ូទ ត្រឹមត្រូវដោយ អាល់ហ្បានី ៖

عن عقبة بن عامر سألت ابنَ مسعودٍ عما يقولُه بعد تكبيراتِ العيدِ قال : (يحمدُ اللهَ ويُثني عليه ويُصلي على النبيِّ) . صححه الألباني في إرواء الغليل 642

ក្នុងន័យនេះដែរ បើសិនជាបុគ្គលនោះសូត្រទូអាអ្វីផ្សេងខុសពីអ្វីដែលបានសរសេរខាងលើ តែក្នុងទូអានោះមានន័យ សរសើរចំពោះអល់ឡោះ និងសឡាតលើរ៉ស៊ូលុលឡោះ ស្ហៃខ អ៊ីបនូ អ៊ូសៃមីន ថា ៖ ទូអារបស់គាត់ គឺត្រឹមត្រូវទាំងអស់ ពីព្រោះវាគ្មានភស្តុតាងណាមួយ ដែលបានកំណត់ថា ត្រូវតែសូត្របែបនេះ ឬបែបនោះឡើយ ។

ហើយ ស្ហៃខ អ៊ីបនូ អ៊ូសៃមីន ថា ៖ បើសិនជាអ្នកមិនសូត្រទូអាអ្វីទាំងអស់នៅចន្លោះតឹកពៀតនីមួយៗ ក៏គ្មានបញ្ហាអ្វីដែរ ពីព្រោះវាជាស៊ុណ្ណះ មិនវ៉ាជិបឡើយ ។

#ការសូត្របន្ទាប់ពីស៊ូរ៉ោះអាល់ហ្វាទីហះ ៖

រ៉ក្អាត់ទី១ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ الفاتحة រួចសូត្រស៊ូរ៉ោះ (سَبِّحِ اسْمَ رَبِّكَ الْأَعْلَى)

ហើយរ៉ក្អាត់ទី២សូត្រ (هَلْ أَتَاكَ حَدِيثُ الْغَاشِيَةِ) ។

ការសូត្រនេះយោងលើហាទីសរាយការណ៍ដោយ អ៊ីម៉ុា អះម៉ាត់ ៖

سمرة بن جندب أنَّ النبيَّ صلى الله عليه وسلم كان يقرأ في العيدين ب { سَبِّحِ اسْمَ رَبِّكَ الأَعْلَى } و { هَلْ أَتَاكَ حَدِيثُ الغَاشِيَةِ } رواه أحمد.

ឬអាចសូត្រម្យ៉ាងទៀតបានដូចគ្នា ៖

រ៉ក្អាត់ទី១ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ الفاتحة រួចសូត្រ ស៊ូរ៉ោះកោហ្វ (ق وَالقُرآنِ المجيدِ)
ហើយរ៉ក្អាត់ទី២សូត្រស៊ូរ៉ោះ (اقْتَرَبَتِ السَّاعَةُ وَانْشَقَّ الْقَمَرُ)
ការសូត្រខាងលើយោងទៅលើហាទីស្សរាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម និង អាស្ហាប៊ុស្សូណិន ៖
أن عمرَ بنَ الخطابِ سأل أبا واقدٍ الليثيِّ: ما كان رسولُ اللهِ صلى الله عليه وسلم يقرأُ به في الفطرِ، والأضحى ؟ قال: كان يقرأُ بـ (ق والقرآنِ المجيدِ) و (اقتربتِ الساعةُ وانشق القمرُ).
صححه الألباني في صحيح الترمذي 543

ដូច ស៊ែស្កខុលតស្លាម អ៊ីបនូ តៃមីយ្យះ ថា ៖ ការសូត្រដូចអ្វីដែលបាននិយាយខាងលើ គឺជាស៊ុណ្ណះ និងជាអ្វីដែលល្អបំផុត តែបើសិនជាសូត្រស៊ូរ៉ោះអ្វីផ្សេងក្រៅពីនោះដូចសឡាតទូទៅក៏គ្មានបញ្ហាអ្វីដែរ សុទ្ធតែត្រឹមត្រូវទាំងអស់ ។

#រឺឯកាយវិការផ្សេងទៀត ដូចជា ឱនរូកួក ងើបពីរូកួកមកវិញ ស៊ូជូទ ងើបពីស៊ូជូទ អង្គុយរវាងស៊ូជូទទាំងពីរ និងស៊ូជូទជាលើកទីពីរ រួចតឹកពៀរងើបពីស៊ូជូទដើម្បីអង្គុយ និងសូត្រតះយ៉ិត ព្រមទាំងសឡាតលើណាពី និងការឲ្យសាឡាមទៅខាងស្តាំនិងខាងឆ្វេង គឺដូចទៅនឹងសឡាតផ្សេងទៀតដែរ ។

Caption

•ឧទាហរណ៍នៃសឡាត

»ការសឡាតវ៉យ៉ាមាន 2 រ៉កអាត់៖

~រ៉កអាត់ទី 1 មាន 7 Takbeer

~រ៉កអាត់ទី 2 មាន 5 Takbeer

»ស៊ូរោះនៅក្នុងសឡាតវ៉ិយ៉ាមាន

•Surah Qaaf
•Surah al-Qamar
រឺ

•Surah al-A’laa
•Surah al-Ghaashiyah

»រ៉ក្អាត់ទី 1

~តឹកពៀតទីមួយរួចសូត្រថា៖

سُبْحَانَكَ اللَّهُمَّ وَبِحَمْدِكَ. تَبَارَكَ اسْمُكَ وَتَعَالَى جَدُّكَ. وَلاَ إِلَهَ غَيْرُكَ". رواه مسلم"

~បន្ទាប់មកតឹកពៀតទាំង 6 និងចន្លោះវាស៊ុណ្ណះត្រូវសូត្រថា ៖

اللهُ أكبرُ كَبِيرًا ، وَالْحَمْدُ لِلَّهِ كثيرًا ، وَسُبْحَانَ اللهِ بُكرةً وَأَصِيلاً ـ اَللَّهُمَّ صَلِّ عَلَى مُحَمَّد
ឬសូត្រម្យ៉ាងទៀតបានដូចគ្នា ៖
الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ - اَللَّهُمَّ صَلِّ عَلَى مُحَمَّد

Caption

(និងសំរាប់សូត្រក្នុងរ៉ក្អាត់ទី 2 ផងដែរ)

~បន្ទាប់ពីតឹកពៀតចំនួន 6 ដងរួចត្រូវសូត្រ ៖

أعوذُ بالله من الشيطانِ الرَّجيمِ

បន្ទាប់មកសូត្រ ៖

بسم الله الرحمن الرحيم

រួចសូត្រ ៖ ស៊ូរ៉ោះ អាល់ហ្វាទីហះ ។

»រ៉ក្កាត់ទី 2

~បន្ទាប់ពីងើបពីស៊ូជូតរួចត្រូវសូត្រតឹកពៀត(الله أكبر)

~បន្ទាប់មកសូត្រតឹកពៀត(الله أكبر) ចំនួន 5 ដង ហើយ
មិនបាច់សូត្រ ៖ أعوذُ بالله من الشيطانِ الرَّجيمِ ទៀតនោះទេ គឺចាប់ផ្តើមពី بسم الله الرحمن الرحيم និងសូត្រស៊ូរ៉ោះ អាល់ហ្វាទីហះតែម្តង ។

(ជនដែលមកមិនទាន់ Takbeer ខ្លះ គឺមិនបាច់ Takbeer សងវិញទេព្រោះវាជាស៊ុណ្ណះ មិនមែនជា Wajib)

•ច្បាប់ទាក់ទងក្នុងសឡាត

~គួរមកឲ្យបានមុនពេលសឡាត
~បន្ទាប់ពីដល់កន្លែងរួច ត្រូវសឡាត

Caption

~បន្ទាប់ពីសឡាតរួច ត្រូវ Khutbah
(កំឡុងពេល Khutbah គឺអនុញ្ញាតិឲ្យចាកចេញព្រោះការស្តាប់ Khutbah រ៉យ៉ាមិនមែនជាកាតព្វកិច្ច តែវាគ្រាន់តែជាស៊ុណ្ណះ)
~មិនត្រូវពន្យាពេលសឡាតរ៉យ៉ា
~គ្មាន Nafil Prayers មុនរឺក្រោយនៃសឡាតរ៉យ៉ាទេ

•ផ្សេងៗ

1.បើស្ថិតក្នុងករណីមិនដឹងថាថ្ងៃដែលបួសជាថ្ងៃ Eid យើង ត្រូវបញ្ឈប់បួស និងថ្ងៃបន្ទាប់ទើបត្រូវសឡាតរ៉យ៉ា

2.ជនដែលមិនបានសឡ្ញាតរ៉េយ៉ាទេ គឺត្រូវសឡ្ញាតសងវិញ 2 រ៉កអាត់
3.ធ្វើដំណើរទៅមកសឡ្ញាតដោយផ្លូវផ្សេងគ្នា

»មុជទឹក

~3 ប្រការគួរធ្វើនៅថ្ងៃ Eid

1.មុជទឹក
2.បរិភោគមុនចេញទៅសឡ្ញាត Eid al-Fitr
3.ដើរទៅសឡ្ញាតរ៉េយ៉ា

~Takbeer

1.Takbeer នៅថ្ងៃ Eid al-Fitr គួរបន្លឺសំលេងខ្លាំងជាង Eid al-Ad’haa
2.Takbeer នៅថ្ងៃ Eid al-Fitr ចាប់ផ្តើមពីយប់នៃ Eid រហូតដល់ Imam ចាប់ផ្តើមសឡ្ញាតរ៉េយ៉ា

~ពាក្យ Takbeer

اللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ، لَاإِلٰهَ إِلَّااللَّهُ وَاللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ وَلِلَّهِ الْحَمْدُ

اللَّهُ أَكْبَرُ كَبِيْرًا وَالْحَمْدُ لِلَّهِ كَثِيرًا وَسُبْحَانَ اللَّهِ بُكْرَةً وأَصِيْلاً, لَاإِلٰهَ إِلَّااللَّهُ وَلَانَعْبُدُ إِلَّاإِيَّاهُ مُخْلِصِيْنَ لَهُ الدِّيْنَ, وَلَوْ كَرِهَ الكَا فِرُونَ, لَاإِلٰهَ إِلَّااللَّهُ وَحْدَهُ, صَدَقَ وَعْدَهُ, وَنَصَرَ عَبْدَهُ, وَأَعَزَّجُنْدَهُ وَهَزَمَ الْأَحْزَابَ وَاحْدَهُ, لَاإِلٰهَ إِلَّااللَّهُ وَاللَّهُ أَكْبَرُ، اللَّهُ أَكْبَرُ وَلِلَّهِ الْحَمْدُ

~ការជូនពរអ្នកដទៃ

មាន 2 ដែលភាគច្រើនគេប្រើ៖

» تقبل الله منا ومنكم «
» Eid Mubaarak



Caption